柬埔寨国情研究课教程

# 柬埔寨民族与习俗

# ជនជាតិនិងប្រពៃណីប្រទេសកម្ពុជា

cambodian folk and custom

编者 钟楠

解放军外国语学院

2005 年 5 月

# បញ្ជីអត្ថបទ


## ក_ជនជាតិខ្មែររស់នៅប្រទេសកម្ពុជា ១

១_ពាក្យថាខ្មែរ---------------------------- ២

២_អំពីជនជាតិកួយ------------------------ ៨

៣_ទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិកាវែត--------- ២៣

៤_ការវិវឌ្ឍន៍ផ្នែកប្រពៃណីរបស់ជនជាតិព្នង---------- ២៩

៥_ខ្មែរកម្ពុជាក្រោមកំពុងប្រឈមមុខនឹងលំបាក--------- ៤១

៦_បងប្អូនជនជាតិចារាយ និងជីវភាពរស់នៅ---------- ៥២

*របៀបធ្វើស្រាពាងរបស់បងប្អូនជនជាតិក្រោល--------- ៥៧

## ខ_ប្រពៃណីទំនៀមទំលាប់ប្រចាំស្រុកខ្មែរ ៦១

១_អំពីប្រក្រតិទិន------------------------ ៦២

៣_ពិធីឡើងអ្នកតា------------------------- ៧១

៤_ស្វែងយល់ពីប្រវត្តិនៃខ្លែងខ្មែរ----------------- ៧៧

៥_ប្រវត្តិព្រះគោព្រះកែវ -------------------- ៨២

៦_ព្រលឹងមេធិយមនៅក្នុងសង្គមខ្មែរ-------------------- ៨៧

*ពិធីឡើងផ្ទះថ្មី-------------------------- ៩៧

៧. ប្រពៃណីចូលម្លប់-------------------------- ១០២

៨. ប្រពៃណីពេលរៀបការ------------------------ ១១៤

១០_ប្រវត្តិសំពះផ្ទឹម-------------------------- ១២៥

១១_ប្រពៃណីនៅពេលស្លាប់---------------------- ១២៩

*ពិធីលាយសពតាមសម័យកាលប្រវត្តិសាស្ត្រ --------- ១៤០

*ប្រពៃណីពាក់ឆៀងរបស់ស្ត្រីខ្មែរ------------ ១៤២

១២. ពិធីបំបួសនាគនៅកម្ពុជា -------------------- ១៤៥

១៣. វិទ្យាស្ថានសិល្បៈនិងវប្បធម៌ (រ៉ៃយំ)-------------- ១៦៤

១៤. អង្គការខ្មែរអភិវឌ្ឍន៍វប្បធម៌ (អ ខ អ វ)------------ ១៦៩

# ក-ជនជាតិខ្លះ

# រស់នៅ

# ប្រទេសកម្ពុជា

# ពាក្យថាខ្មែរ

សៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោកសាស្ត្រាចារ្យត្រឹង_ងា បានបញ្ជាក់ថាការស្រាវជ្រាវពី ខ្មែរ. តែងឃើញបញ្ហាចោទឡើងចំពោះពាក្យថា **ខ្មែរ_មន_កម្ពុជា** នេះឯង។ អ្នកសិក្សាស្រាវជ្រាវបានផ្តល់យោបល់ច្រើនបែបច្រើនយ៉ាងណាស់ចំពោះពាក្យទាំងបីខាងលើ។

ក្នុងបណ្តាសម្មតិកម្មជាច្រើនយើងសង្កេតឃើញសម្មតិកម្មរបស់លោក ហ្សកសឺដេស( G. Coedes ) អ្នកស្រាវជ្រាវជនជាតិបារាំងហាក់មានមូលបទច្រើនសមទំនងនឹងអាចបកស្រាយរកឃើញឫសគល់នៃពាក្យថា **ខ្មែរ** នេះបាន ។

_ខ្មែរយើងនិយមហៅខ្លួនឯងថា.ខ្មែរ. គឺពុំបានហៅខ្លួនឯងថា **កម្ពុជា**. នោះទេ សូម្បីពាក្យថា **កម្ពុជា** នេះក៏អ្នកស្រុកជាទូទៅច្រើនហៅថា **ស្រុកខ្មែរ**. ដែរ។ សៀវភៅប្រវត្តិសាស្ត្រខ្មែររបស់សាស្ត្រាចារ្យ ត្រឹង_ងា **បានអះអាងថា** : ពាក្យ **ខ្មែរ**. នេះច្បាស់ជាបានក្លាយមកពីពាក្យ **ខ្មេរ** ក្នុងសម័យអង្គរដែលបានក្លាយមកពី **ក្មេរ** ទៀតពីសម័យមុនអង្គរ។ ឯពាក្យ **កម្ពុជា** បានក្លាយមកពីពាក្យ **កម្វុជ** ដែលមានប្រើក្នុងសិលាចារឹកព្រះគោឬ **កម្វុជទេស** ក្នុងសិលាចារឹក

បន្ទាយឆ្មារ។ សិលាចារឹកចាមក៏បានប្រើពាក្យកម្ពុ [illegible] សំដៅលើ [illegible] ប្រទេសខ្មែរយើងដែរ។ សិលាចារឹកបក្សីចាំក្រុងនៅសតវត្សទី១០ បានពន្យល់ថា ស្តេចកម្ពុជាមានដើមកំណើតមកពីឥសី កម្ពុ និងនាងអប្សរ មេរា ឃើញថាពាក្យ **កម្ពុជ** មានជាប់ទាក់ទងនឹងស្តេចឬរាជវង្សនេះច្រើន ។...... ត្រង់នេះហើយទើបអ្នកប្រាជ្ញបានយល់ថា ពាក្យ ខ្មែរ ប្រហែលជាកើតមកពីការផ្សំរវាងឈ្មោះ **កម្ពុ** និងមេរាដោយសំអាងទៅលើរឿងនិទានក្នុងសិលាចារឹកបក្សីចាំក្រុងនេះឯង។ ឯព្រះភិក្ខុវិរិយបណ្ឌិតោ ប៉ាង ខាត់ក៏មានយល់ស្របតាមទស្សនៈនេះនាំស្រុងដែរ ។ពីអំណានសូររបស់ពាក្យ កម្ពុ មេរា [illegible] ប្រែក្លាយទៅជាពាក្យថា ខ្មែរ នេះមានដូចខាងក្រោម ៖

**កម្ពុ+មេរា** = កម្ពុមេរា > កម្ពុ+មេរ = កម្ពុមេរ > កម្ពុ+មេរ = កម្ពុមេរ>កម **+មេរ** = កមេរ >ក្មេរ> ខ្មែរ

ហើយមកដល់សម័យលង្វែក_ឧត្តុង្គ_ភ្នំពេញក៏ប្រែទៅជា ខ្មែរ រហូតមកដល់សព្វថ្ងៃ ។

ចំណែកពាក្យ កម្ពុជា ក៏មានជាប់ទាក់ទងទៅនឹងឈ្មោះរបស់តាបសឥសីព្រះនាម **កម្ពុ** នេះដែរ ។ តាបស **កម្ពុ**នេះ [illegible]

ទទួលឋានន្តរនាមថា **កម្ពុស្វ័យម្ភូ** ។ សិលាចារឹកបានកត់ត្រាតាមបែបជាទេវកថាថាព្រះមហេសីនាមនាង **មេរា** គឺជាស្រីទេពអប្សរដែលព្រះឥស្សរប្រទានអោយ ។

ពាក្យ **ស្វ័យម្ភូ** មានន័យថាជាអ្នកកើតឯង ដូចជាព្រះអាទិទេពមួយអង្គគឺជាអ្នកសំរេចបានគុណវិសេសដោយឯកឯង។ បើយោលទៅលើទស្សនៈសន្តតិវង្សនេះហើយ ដែលបានទៅគ្រប់គ្រងទឹកដីចេនឡាមុនគេបង្អស់ដោយមានរាជធានីឈ្មោះ**តចុះ**នៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័ន ដែលមានមហេសីព្រះនាម **កម្ពុជរាជលក្សី** ជារាជវង្សានុវង្សនៃសន្តតិវង្ស **កម្ពុ** នេះ។ព្រះបាទភវវរ្ម័ន នេះហើយដែលបានចាប់ផ្តើមវាយយកនគរភ្នំដែលជារដ្ឋអំណាចកណ្តាលដាក់ជាចំណុះ ។ ចាប់ផ្តើមតាំងពីពេលនោះឈ្មោះនគរភ្នំត្រូវប្តូរទៅជានគរ **កម្ពុជ** ឬ **កម្ពុជទេស** វិញ ។ ប្រហែលដោយសារឥទ្ធិពលអំណាចខាងដើមដ៏ខ្លាំងក្លារបស់សន្តតិវង្ស **កម្ពុ_មេរា** នេះទើបពាក្យ **ចេនឡា** នៅតែបានប្រើប្រាស់រៀងរហូតមក។ព្រះបាទជ័យវរ្ម័នទី២ ក៏ជាស្តេចមានប្រភពកំណើតនៅចេនឡានៃសន្តតិវង្ស **កម្ពុ_មេរា** នេះដែរ ។ ព្រះអង្គគឺជាស្ថាបនិករាជធានីដើមដំបូងនៃសម័យអង្គរ។ មកដល់សម័យអង្គរនេះទើបពាក្យថា **កម្ពុជ**

ឬ **កម្វុជទេស** ត្រូវបានអ្នកស្រាវជ្រាវគេឃើញជាញឹកញាប់នៅតាមសីលាចារឹកនានា ។

ដូច្នេះពាក្យថា **កម្វុជ** ឬ **កម្វុជទេស** ឬក៏ថា **កម្ពុជ** ឬ **កម្ពុជា** នេះគឺជាពាក្យសំរាប់កំណត់ហៅប្រទេសខ្មែរ ដោយពិតដោយវិធីធ្វើសំយោគរវាងពាក្យ **កម្ពុ** និងពាក្យ **ជុជះ** កើតបានជាពាក្យ **កម្វុជះ** ឬ **កម្វុជទេស** ដែលមានន័យថាជាប្រទេសរបស់ពូជពង្សវង្សត្រកូលរបស់សន្តតិវង្ស **កម្ពុ_មេរា** នោះ ។

_ឃើញថាពាក្យ **កម្វុជះ** ឬ **កម្ពុជា** នេះជាពាក្យផ្លូវការកើតឡើងចេញពីប្រភពមន្ត្រីរដ្ឋបាលរបស់អំណាចកណ្តាលដែលដើមឡើយ គឺជាជនជាតិឥណ្ឌាប្រើភាសាអក្សរសំស្ក្រឹតក្រោយមកទើបមានប្រើភាសាបាលីនៅចុងសម័យអង្គរ (១៣០៩)ដោយពិតគឺជាពាក្យមានអត្ថន័យជាក់លាក់ព្រោះកើតឡើងពីវិធីធ្វើសំយោគពាក្យរបស់អ្នកប្រាជ្ញអក្សរសាស្ត្រ ។

_ចំណែកពាក្យថា **ក្មែរ ខ្មេរ** សព្វថ្ងៃហៅថា **ខ្មែរ** នេះអាចសន្និដ្ឋានបានថាជាពាក្យកើតចេញពីប្រភពអ្នកស្រុកអ្នកភូមិទេ ដែលបានកំណត់ឈ្មោះហៅក្រុមពួកតំបន់របស់ខ្លួនទៅតាមពួកមេកើយសន្តតិវង្សដែលជាអ្នកគ្រប់គ្រងខ្លួន ។

ដោយសារ ... ទុក... **កម្ពុ_ជោ** មានឧត្តមភាពល្បីល្បាញទាំងខាងសាសនា បានថាទមទាមជាសន្តតិវង្សរបស់ព្រះអាទិទេព ទាំងលើអំណាចរដ្ឋបាល ព្រមគ្រប់គ្រងត្រួតត្រាគ្រប់គ្រងបង្រួមទឹកដីដ៏ធំល្វឹងល្វើយជាហេតុធ្វើអោយសន្តតិវង្ស **កម្ពុជោ** មានឥទ្ធិពលយ៉ាងខ្លាំង ។ ប្រជាពលរដ្ឋទូទៅភាគច្រើនលើសលប់ ព្រមទទួលយកពាក្យ **កម្ពុ_ជោ** មកប្រើប្រាស់ទុកជាមេកើយរបស់ខ្លួន ។ ក៏ប៉ុន្តែដោយសារពាក្យ **កម្ពុ_ជោ** ជាពាក្យជាភាសាបរទេសពុំមែនជាពាក្យជាភាសារបស់ខ្លួនជាពាក្យចំណៀលថ្មីប្រជាជនខ្មែរពុំអាចបញ្ចេញសំណៀរទៅតាមរូបស័ព្ទដើមទាំងស្រុងបានព្រោះខុសទម្លាប់ ។ ទើបពាក្យ**កម្ពុ_ជោ** ចុងក្រោយប្រជាជនសាមញ្ញទូទៅហៅបានត្រឹមថា **ក្មេរ>ខ្មេរ> ខ្មែរ** នេះតែម្តងទៅដែរ ។

ចំណែកឯអំបូរ **ខ្មែរ_មន** ជាច្រើនទៀតដែលមិនស្ថិតនៅក្រោមអំណាចអារ្យធម៌ វប្បធម៌របស់រដ្ឋបាល **កម្ពុជទេស**ក៏បានរក្សាឈ្មោះដើមសម្រាប់ហៅជនជាតិរបស់ខ្លួន ដែលកំពុងរស់នៅលើទឹកដីប្រទេសកម្ពុជាតែមួយ រហូតមកដល់សព្វថ្ងៃនេះ ។

## ពាក្យថ្មី

| | | | |
|---|---|---|---|
| សម្មតិកម្ម | 假定，假说 | មូលបទ | 理由，动机 |
| ឥសី | 隐士，苦修者，禁欲者 | នាងអប្សរ | 仙女 |
| តាបស | 隐士，苦修者 | ឋានន្តរ | 阶级，官衔 |
| ព្រះឥសូរ | 湿婆神 | សន្តតិវង្ស | 不平坦，世袭<br>不平坦，世家 |

**លំហាត់:**

**ក សូមបំពេញចន្លោះខាងក្រោម:**

១ ស្ដេចកម្ពុជាមានដើមកំណើតមកពីឥសី____និងនាងអប្សរ______ ឃើញថាពាក្យ **កម្ពុជ** មាន____________នឹងស្ដេចឬរាជវង្សនេះច្រើន ។

២ ព្រះមហេសីនាមនាង **មេរា** គឺជាស្រីទេពអប្សរដែល____ ____________________។

៣ តាមទស្សនៈហិណ្ឌូនិយមឃើញថា សន្តតិវង្ស **កម្ពុ_មេរា** នេះគឺជា______________________________នាសម័យនោះ។

៤ ____________គឺជាស្ថាបនិករាជធានីដើមដំបូងនៃសម័យអង្គរ។

៥ ពីព្រោះ_______________ ទើបពាក្យ**គម្ពុ_មេរា** ចុងក្រោយ ប្រជាជនសាមញ្ញទូទៅហៅបានត្រឹមថា **ក្មេរ>ខ្មេរ> ខ្មែរ** នេះតែម្តងទៅដែរ ។

ខ សំនួរ:

១ តើ ឈ្មោះនគរភ្នំត្រូវដូរទៅជានគរ **កម្ពុជ** ឬ **កម្ពុជទេស** នៅពេលណា ?

២ តើពាក្យ កម្ពុជា កើតពីពាក្យអ្វី ?

៣ នៅពេលណា ប្រទេសកម្ពុជាទើបមានប្រើភាសាបាលី ? ប្រើភាសានេះមានន័យយ៉ាងម៉េច ?

គ **សូមរើសខតម្រូវ: តើពាក្យ ខ្មែរ កើតមកពីអី ?**

A មេរា B ខ្មែរ C កម្ពុ D កម្ពុនិងមេរា

## អំពីជនជាតិភួយ

នៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិជាច្រើនដូចជា ភ្នង ជង គួយ ស្ទៀង រដែ ស្ទូច ព័រ ជាដើម។ ពួកនេះចូលចិត្តរស់នៅ

此为试读，需要完整PDF请访问：www.ertongbook

តំបន់ព្រៃភ្នំ ឆ្ងាយពីសង្គមស៊ីវិល័យ។ ជនជាតិទាំងនេះ មានរបៀបរបប រស់នៅ ភាសា ប្រពៃណី និងទំនៀមទម្លាប់ប្លែកៗគ្នា។ នៅពេលនេះខ្ញុំសូមលើកយកជនជាតិគួយ នៅខេត្តកំពង់ធំមកជម្រាបជូនដូតទៅៈ

**១_អំពីទម្រង់រូបរាង និងសម្លៀកបំពាក់**

**ក_គួយប្រុសៈ** មានរូបរាងប្រហែលខ្មែរនៅស្រុកលើដែរ បបូរមាត់ក្រើមសម្បុរសណ្តែកបាយ ស្លៀកខោខ្លី ឬសំពត់ចងក្បិន ពាក់អាវតាមសម័យនិយមខ្លះ ឬអាវបំពង់ពណ៌ខ្មៅ។ សម្តីនិយាយច្រើនបង្ហួសចុងឃ្លា។ តាមការកត់សម្គាល់គួយច្រើនមានចិត្តប្រែប្រួល និយាយមិនសូវទៀងទាត់។ ចង់ទប់ទល់ពួកនេះទាល់តែប្រកាន់ភាពម៉ឺងម៉ាត់ ទើបសម្រេច ហើយកោតញញើតលែងហ៊ានធ្វើផ្តេសផ្តាស។

**ខ_គួយស្រីៈ** ទម្រង់រូបរាងមិនខុសពីស្រីខ្មែរយើងប៉ុន្មានឡើយ។ ស្រីៗទុកសក់បួងគ្រប់គ្នា តែផ្នួងមានទំហំតូច ប្រហាក់ប្រហែលនិងផ្នួងពួកបារគូ។ គេនិយមស្លៀកសំពត់សំឡុយ ឬចងក្បិន តែក្បិនគេច្រើនរិតកប់ដល់គល់ភ្លៅ។ ស្រីចាស់ ច្រើនតែយកអាវមកចងពាតរិតយកខ្លួន គេមិនសូវពាក់ទេ។ គួយក្រមុំពាក់អាវជានិច្ច។ ហើយជួនកាលមានថែម

ដណ្តប់ក្រម៉ាពីលើអាវទៀតផង។ គេពាក់តែងលម្អខ្លួនដោយខ្សែកប្រាក់ ឬពាក់ចារុំដោតខ្សែអំបោះ។ នៅកដៃមានពាក់កងប្រាក់ ឬស្ពាន់ស។ ពួកនាងស្រឡាញ់អង្កាំលើសអ្វីៗទាំងអស់។ គេយកមកពាក់ធ្វើខ្សែក ឬខ្សែដៃ។ ម្រាមដៃសឹងលម្អដោយចិញ្ចៀនប្រាក់ ឬស្ពាន់ តែពុំមានដាំត្បូងទេ។ ក្រមុំៗនិយមយកផ្កាឈើក្រអូបមកសៀតត្រចៀក ឬសៀតផ្នួងសក់ ដើម្បីលើកសម្រស់។ ស្រីកួយមានទំនៀមទម្លាប់ចោះត្រចៀកពាក់ក្រវិល ឬការដែរ។

**២_អំពីជំនឿសាសនា:**

ក្រៅពីជឿលើអារុក្ខ អារក្សអ្នកតា ជនជាតិកួយក៏ជឿហើយ កាន់ព្រះពុទ្ធ សាសនា(២) ផង ដែរ។ មានវត្ត កួយ មួយ សម្រាប់ស្រុកកំពង់ស្វាយ និងស្រុករវៀង ដែលមានព្រះសង្ឃសុទ្ធតែជាជនជាតិកួយបួសនៅក្នុងវត្តព្រៃទទឹងនោះ។ តាមការបញ្ញត្តិរបស់វិន័យ លោកសង្ឃកួយមិនអនុញ្ញាតឱ្យនិយាយភាសាកួយឡើយ។ ការប្រាស្រ័យទាក់ទងគ្នាគ្រប់យ៉ាងត្រូវនិយាយជាភាសាខ្មែរ។ ទាល់តែចាកសិក្ខាបទមកជាគ្រហស្ថវិញ ទើបនិយាយកំណើតបាន។

**៣_អំពីសិល្បៈ÷**

ជនជាតិកួយគ្មានបទចម្រៀងប្រចាំពូជសាសន៍ទេ។ គេច្រៀងតាមតែបទចម្រៀងខ្មែរ។ ក្រៅពីនេះ កួយចេះផ្លុំប៉ីពកប្រគំបទពិរោះលន្លង់លន្លោច និងផ្លុំប្រគួកស្នែងជាបទងាយៗ ឬវាយអង្គួច។ សម្លេងអង្គួចមិនមែនគ្រាន់តែប្រគំសាច់ភ្លេងប៉ុណ្ណោះឡើយ ប៉ុន្តែក៏អាចប្រើជាសញ្ញាឆ្លើយឆ្លងរវាងក្រមុំ និងលោកកំលោះទៀតផង។

**៤_អំពីអក្សរសាស្ត្រ និងភាសា**

ជនជាតិកួយគ្មានអក្សរទេ។ អ្នកបួសក្នុងព្រះពុទ្ធសាសនារៀនតែអក្សរខ្មែរ ហើយសូត្រធម៌ជាបាលី ប្រែជាខ្មែរដូចព្រះសង្ឃយើងដែរ។ ភាសានិយាយរបស់គេស្រដៀងគ្នានឹងចាមនិយាយខ្មែរ។

| ពាក្យខ្មែរ | ពាក្យកួយ |
|---|---|
| ត្រី | កា |
| ឆ្កែ | ច |
| ប្រាក់ | ផ្រាក់ |
| ស៊ីបាយ | ចាដូយ |

ការរាប់ចំនួន មានពាក្យអាចយកមកប្រើប្រាស់បានតែពី ១ ទៅដល់ ២៩។ ចាប់ពី ៣០ ឡើងទៅប្រើតាមពាក្យខ្មែរទាំងអស់។

## ៥_អំពីរបរកស៊ី

ដើម្បីចិញ្ចឹមជីវិត ជនជាតិកួយប្រកបរបរកសិកម្ម ជាមូលដ្ឋាន។ គេធ្វើស្រែ ២ ឬ ៣ ក្បែរៗភូមិ ធ្វើរបៀបលេងៗសោះតែ ខាន។ គេនិយមធ្វើចម្ការ តាមរបៀបកាប់ព្រៃដុត រួចដាំស្រូវ ពោត សណ្តែកទ្រើង ល្ង ល្ពៅ ននោង។ ដំណាំផ្សេងៗត្រូវបានដាំចម្រុះគ្នានៅក្នុង ចម្ការតែមួយ។ ក្រឡាផ្ទៃនៃចម្ការមានពី ១ ទៅ ២ ហិកតា។ គ្រួសារ នីមួយៗចិញ្ចឹមគោញី ១ ឬ ២ ចិញ្ចឹមមេមាន់ ២ ឬ ៣ក្បាល។ ក្រៅពីរបប ធ្វើស្រែចម្ការ ជនជាតិកួយរកស៊ីកាប់ឈើចាំងជាហុប ធ្វើទូក ត្បាញបូស្ស៊ី ឬ ធ្វើធ្នូ ធ្វើដំបូលរនេះ ធ្វើគ្រួស(៣)ចន្លុះ ដងជ័រទឹក បេះជ័រចុង បោចវល្លិ៍ ផ្តៅ ដំដែកធ្វើកាំបិត ពូថៅ ជីង។ល។ ស្រីៗត្បាញរវៃអំបោះជួនកាលធ្វើ សូត្របន្តិចបន្តួចផងដែរ។ ប្រុសៗចូលចិត្តបរបាញ់ ដាក់អន្ទាក់ ទាក់សត្វព្រៃ ព្រោះពួកនេះប៉ិនប្រសប់នឹងស្គាល់ដានសត្វគ្រប់យ៉ាង។

## ៦_អំពីទីលំនៅ:

កាលណាកាប់ព្រៃរួចហើយគេយកភ្លើងទៅដុតឱ្យទៅជា ផេះ។ គេនាំគ្នាទៅសង់រោងតាមពួកក្រុមដូចនៅឯភូមិដែរ។ រោងនៅចម្ការក៏

ដូចនៅភូមិមានប្រវែងទទឹង ៣ ទៅ ៤ ម៉ែត្រ បណ្តោយ ៥ ទៅ ៦ម៉ែត្រ។ សសរខ្ទមធ្វើពីឈើប៉ុនៗចុងភ្លៅ ឬប៉ុនកំភួនជើង ដាំញឹកស្មេកជិតៗគ្នា ធ្វើជាចន្ទល់។ ខ្ទមទាំងនោះមានកម្ពស់ពី ១,៦០ម ទៅ ១,៨០ម។ រនាបធ្វើពីកូនឈើតូចៗត្រង់ៗ ដែលក្រងវែងនឹងវល្លិ៍ ឬចម្រៀងឬស្សីឱ្យជាប់គ្នាជាកម្រង។ ចង្ក្រាននៅលើផ្ទះសម្រាប់ស្ងួដណ្តាំ។ ឯចង្ក្រាននៅក្រោមផ្ទះ សម្រាប់បង្កាត់ភ្លើង អាំង ឆ្អើរ ទាំងយប់ ទាំងថ្ងៃ។ គេយកស្លឹកផ្តៅសោម(៤) មកតម្រៀបចងក្រងជាផ្ទាំងៗសម្រាប់ប្រក់ដំបូល។ ជណ្តើរជួនគ្មាន។ ដើម្បីឡើងលើផ្ទះគេយកឈើសណ្តូកមកដាក់តងលើមាត់ទ្វារខ្ទម ផ្អែករាងទ្រេតបន្តិច។ ជញ្ជាំងផ្ទះមិនមានភាពតត់មត់ជិតម៉ត់ប៉ុន្មានទេ។ ដូច្នេះ អ្នកផងអាចមើលឃើញអ្វីៗនៅក្នុងផ្ទះទាំងអស់។

**៧_លក្ខណៈពិសេសរបស់ជនជាតិគួយ**

ជនជាតិគួយមានចំណុចខ្លាំងពីរយ៉ាង គឺៈ

**ក.ទី**ពូកែខាងដើរលឿន ទាំងស្រី ទាំងប្រុស ហើយមានអំណត់អត់ធន់។ គេអាចទូល រែករបស់ធ្ងន់ៗក្នុងដំណើរទៅកាន់ទីឆ្ងាយបាន ដោយពុំសូវអស់អន់អ្វីប៉ុន្មានឡើយ។ ល្បឿនដែលគួយដើរ ស្មើនឹង

ល្បៀនដែលខ្មែរយើងរត់ត្រឹកៗ។

ខទីពួកៃខាងមិនខ្លាចខ្មោចព្រាយបីសាច មិនខ្លាចសត្វ

សាហាវ មានខ្លាឃ្មុំជាដើម។

៨. ប្រពៃណីផ្សេងរបស់សាសន៍ក្ងួយ

ជនជាតិក្ងួយខ្លាចជំងឺណាស់។ កាលបើជំងឺឆ្លងចូលមក

រាតត្បាត ហើយបណ្តាលឱ្យមានមនុស្សស្លាប់ ពីរ ឬបីនាក់នោះអ្នកស្រុក

ទាំងអស់នាំគ្នារត់ចោលភូមិទៅនៅយោយព្រៃ បែកខ្ញែកគ្នាអស់។ ទាល់តែជំងឺ

នេះបានកន្លងផុតទៅ ទើបវិលត្រឡប់ចូលមកនៅក្នុងភូមិវិញ។ ខ្លះទៀតទៅ

បាត់រហូតមិនវិលវិញទេ។

កំលោះក្ងួយមិនសូវស្រវាប្រទេញរៀសរវៃក្នុងការងារ

ទេ។ ពេលយប់គេតែងនាំគ្នាទៅលួចក្រមុំៗ។ សូមជម្រាបថា ក្រមុំក្ងួយ

ទាំងអស់ ករម្រមានដោះបរិសុទ្ធណាស់ ដោយហេតុពួកកំលោះមកលួចលេង

រៀងរាល់យប់។ ក្រមុំក្ងួយមានទម្លាប់បុកអង្ករ ឬស្រូវ យកដៃគ្នានៅផ្ទះណា

មួយដែលគេបានណាត់គ្នាមកជាមុន។ ស្រីៗបុកអង្ករក្នុងចង្វាក់ញាប់រន្ថើន។

ដើម្បីឱ្យលាន់ឮសម្លេងអង្រែខ្ទាំរទៅបានឆ្ងាយ គេជីកលុងដីពីក្រោយបាតត្បាល់

此为试读，需要完整PDF请访问： www.ertongbook